

# ទម្លាយភាពស្ងៀមស្ងាត់

## បញ្ចប់និទណ្ឌភាពចំពោះ អំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជា

**AMNESTY**
**INTERNATIONAL**



ទម្លាយភាពស្ងៀមស្ងាត់

បញ្ចប់និទណ្ឌភាពចំពោះ អំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជា

AMNESTY
INTERNATIONAL

សូមកាត់យកប្រៃសណីយបត្រនិងរក្សាទុកផ្នែកនេះ

# ទម្លាយភាពស្ងៀមស្ងាត់
# បញ្ចប់និទណ្ឌភាពចំពោះអំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជា

របាយការណ៍ស្ដីពីស្ត្រី និងកុមារីដែលទទួលរងការរំលោភសេពសន្ថវៈកំពុងកើនឡើងនៅក្នុងប្រទេសកម្ពុជា ។ អំពើពុករលួយនិងការរើសអើងក្នុងជួរនគរបាលនិងតុលាការរារាំងជនរងគ្រោះនៃអំពើរំលោភសន្ថវៈពីការទទួលបានយុត្តិធម៌ ។ ស្ត្រីនិងកុមារីដែលព្យាយាមរាយការណ៍អំពីបទឧក្រិដ្ឋទាំងនេះ បានប្រឈមមុខនឹងការជំរិតទារប្រាក់ ការមិនអើពើ និងការអស់ជំនឿលើមន្ត្រី ។

ពួកគេក៏ប្រឈមមុខនឹងការខ្វះខាតធ្ងន់ធ្ងរនូវសេវាព្យាបាលវេជ្ជសាស្ត្រនិងការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម ដែលឆ្លុះបញ្ចាំងឱ្យឃើញនូវផ្នត់គំនិតសង្គមមកលើបទរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទផ្សេងៗទៀត ។

មុន្នី អាយុ ១៩ ឆ្នាំ ដែលមានពិការភាពខាងបញ្ញាសិក្សាបានទទួលរងការរំលោភសេពសន្ថវៈនៅចុងឆ្នាំ ២០០៩ ។ គ្រួសាររបស់នាងបានពន្យល់អំពីរបៀបដែលមន្ត្រីនគរបាលមិនអើពើចំពោះពាក្យបណ្ដឹងរបស់ខ្លួន បន្ទាប់ពីទទួលរងការរំលោភសេពសន្ថវៈ ។ ឪពុករបស់មុន្នីបាននិយាយថា កូនស្រីរបស់គាត់រស់ក្នុងភាពភ័យខ្លាចជានិច្ចចំពោះជនល្មើសដែលនៅរួចខ្លួន ។ គ្រួសារនាងបានខិតខំតស៊ូ ដើម្បីលៃលករកប្រាក់ទិញថ្នាំពេទ្យដែលនាងត្រូវការ ហើយនិយាយរៀបរាប់អំពីថ្លៃធ្វើដំណើរទៅជួបតុលាការ និងនគរបាលថាជារឿងពិបាកខ្លាំងណាស់ ។

ឪពុករបស់នាងបាននិយាយដូច្នេះថា "ប៉ូលីសធ្វើការតែពេលដែលយើងមានលុយទេ បើមានលុយបង់ឱ្យ ។ ឱ្យដប់ម៉ឺនរៀល [ប្រហែល ២៥ ដុល្លារអាមេរិក] សម្រាប់ធ្វើការចាប់ខ្លួនអ្នកណាម្នាក់ ។ តែពួកខ្ញុំអត់លុយទេ" ។

## ចាត់វិធានការឥឡូវនេះ!

សូមចុះហត្ថលេខា រួចផ្ញើរប្រៃសណីយបត្រនេះទៅរាជរដ្ឋាភិបាលកម្ពុជា

AMNESTY INTERNATIONAL

រូបភាព : ផ្សារចាស់ ទីក្រុងសៀមរាប
កម្ពុជា ។ ខែវិច្ឆិកា ឆ្នាំ២០១០ ។ © បិនធនសុន
លិបិក្រម : ASA 23/003/2010

AMNESTY INTERNATIONAL

## សម្ដេចជាទីគោរព

ខ្ញុំបាទ/នាងខ្ញុំ សូមជំរុញរាជរដ្ឋាភិបាលកម្ពុជា បំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនក្រោមអនុសញ្ញា អ.ស.ប ស្ដីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងនឹងស្ត្រីភេទ :

- សូមទម្លាយភាពស្ងៀមស្ងាត់ និងសូមថ្កោលទោសជាសាធារណៈ ចំពោះអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទដទៃទៀត ប្រឆាំងស្ត្រីភេទនិងកុមារី ដើម្បីបង្ហាញថា បទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបែបនេះ នឹងមិនត្រូវអត់ឱនឱ្យបានឡើយ ហើយដើម្បីទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះ ។
- សូមដោះស្រាយយ៉ាងម៉ឺងម៉ាត់ ចំពោះការអនុវត្តនច្បាប់ដែលខ្វះខាត ការដោះស្រាយក្រៅប្រព័ន្ធតុលាការ ការកាត់ទោសដ៏ទន់ខ្សោយ និងអំពើពុករលួយដ៏រីករាលដាល ដើម្បីធ្វើឱ្យជនល្មើសទទួលទណ្ឌកម្ម និងជនរងគ្រោះទទួលបានយុត្តិធម៌ ។
- សូមដោះស្រាយការខកខានពេលបច្ចុប្បន្នរបស់រដ្ឋាភិបាល ក្នុងការផ្ដល់ឱ្យជនរងគ្រោះនូវសំណងជំងឺចិត្តដ៏សមស្របរួមទាំងសេវាព្យាបាលសុខភាពនិងសេវាចិត្តសាស្ត្រសង្គម ។

សូមទទួលនូវសេចក្ដីគោរពរាប់អានអំពីខ្ញុំ ។

ឈ្មោះ ______________________

ប្រទេស ______________________

Index: ASA 23/003/2010

His Excellency Samdech Hun Sen
Prime Minister
Office of the Prime Minister
Phnom Penh
Cambodia

រូបភាព : កុមារីកម្ពុជានៅមុខព្រះបរមរាជវាំង
ភ្នំពេញ កម្ពុជា ខែមករា ឆ្នាំ២០១០
© AP/PA រូបថត/ហេងស៊ីនិត

Amnesty International, International Secretariat, Peter Benenson House, 1 Easton Street, London WC1X 0DW, United Kingdom. www.amnesty.org